00986532 E305/6

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-May-2014, 15:35
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** (ដោយមានឧបសម្ព័ន្ធសម្ងាត់ចំនួន៥ គឺ ឧបសម្ព័ន្ធ I, II, IIក, III និង IIIក)

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**បញ្ជីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយ សហព្រះរាជអាជ្ញា និងសេចក្ដីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿងលេខ០០២/០២ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន៥៖ I, II, IIក, III និង IIIក)**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSÉ

# សេចក្តីសន្និដ្ឋាន

១- អនុលោមតាម "សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមក្នុងសំណុំរឿងលេខ០០២ និងវិសាលភាពនៃសំណុំរឿងលេខ០០២/០២" របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤[1] និងដីកាបង្គាប់របស់អង្គជំនុំជម្រះ "ស្តីពីការដាក់ឯកសារដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីត្រៀមរៀបចំសម្រាប់ការជំនុំជម្រះក្តីលើសំណុំរឿលេខ០០២/០២" ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤[2] សហព្រះរាជអាជ្ញាដាក់ជូននូវបញ្ជីរបស់ខ្លួន និងសេចក្តីសង្ខេបដែលទាក់ទងនឹងសាក្សី ដើម្បណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនានាដែលស្នើឡើង នឹងត្រូវស្តាប់ចម្លើយនៅក្នុងពេលជំនុំជម្រះក្នុងសំណុំរឿងលេខ០០២/០២ ដូចមាននៅក្នុងឧបសម្ព័ន្ធសម្ងាត់ចំនួនប្រាំ ដែលភ្ជាប់មកជាមួយដូចខាងក្រោមនេះ៖

(១) **ឧបសម្ពន្ធទីI៖** បញ្ជីរួមបញ្ចូលគ្នានៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (រួមទាំងឈ្មោះបម្រុង) សម្រាប់សវនាការសំណុំរឿងលេខ០០២/០២ តាមលំដាប់លំដោយដែលបានស្នើ សម្រាប់វគ្គសវនាការ និងការចូលខ្លួន។

(២) **ឧបសម្ព័ន្ធទីII៖** បញ្ជីបច្ចុប្បន្នភាពនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើង

(៣) **ឧបសម្ព័ន្ធទីIIក៖** បញ្ជីបច្ចុប្បន្នភាពនៃសាក្សីបម្រុង ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (បម្រុង) ដែលបានស្នើឡើង

(៤) **ឧបសម្ព័ន្ធទីIII៖** ព័ត៌មានបច្ចុប្បន្នភាព(សេចក្តីសង្ខេប) ដែលតម្រូវចាំបាច់ទាក់ទងនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើបានឡើង និង

---

[1] ឯកសារលេខ **E301/9/1** សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមក្នុងសំណុំរឿងលេខ០០២ និងវិសាលភាពនៃសំណុំរឿងលេខ០០២/០២, ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤។

[2] ឯកសារលេខ**E305** ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដែលធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤។

(៥) **ឧបសម្ព័ន្ធទីIIIក៖** ព័ត៌មានបច្ចុប្បន្នភាព (សេចក្តីសង្ខេប) ដែលតម្រូវចាំបាច់ទាក់ទងនឹងសាក្សីបម្រុង ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (បម្រុង) ដែលបានស្នើ។

២- នៅក្នុង**ឧបសម្ព័ន្ធទី**I, **ទី**II និង**ទី**III ដែលរួមបញ្ចូលគ្នា មានឈ្មោះ និងចំណុចពិសេសផ្សេងៗទៀតនៃ **សាក្សីចំនួន៩៧នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២នាក់ និងអ្នកជំនាញចំនួន៨នាក់** ដែលសហព្រះរាជអាជ្ញាស្នើឡើងដើម្បីស្តាប់សក្ខីកម្មនៅពេលជំនុំជម្រះ។ នៅក្នុងចំណុចពិសេសផ្សេងៗដែលបានផ្តល់ជូនរួមមាន កម្រិតដែលព័ត៌មាននេះមានសម្រាប់ឲ្យសហព្រះរាជអាជ្ញាងាយរកបាន៖ ភេទរបស់បុគ្គលម្នាក់ៗ, ទីកន្លែង និងថ្ងៃខែឆ្នាំកំណើត, អាសយដ្ឋានបច្ចុប្បន្ន និងព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង, លេខយោងនៃឯកសារនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលមានការជាប់ទាក់ទងខ្លាំងរបស់បុគ្គលនោះ, ប្រភេទនៃសម្បថដែលរំពឹងទុកថាបុគ្គលម្នាក់ៗ នឹងត្រូវធ្វើ ឬជម្រើសផ្សេងទៀតក្នុងករណីបើសិនមិនតម្រូវឲ្យធ្វើសម្បថ ទំនាក់ទំនងរបស់ពួកគេជាមួយបុគ្គលនានានៅក្នុងករណីដែលពួកគេត្រូវបានច្រានចោលជាមុនមិនឲ្យធ្វើសម្បថ ដូចដែលមានចែងនៅក្នុងវិធាន២៤(២)នៃវិធានផ្ទៃក្នុង។ ភាសាដែលរំពឹងទុកសម្រាប់ការធ្វើសក្ខីកម្មរបស់បុគ្គល និងរយៈពេលប៉ាន់ស្មានដែលតម្រូវសម្រាប់ការផ្តល់សក្ខីកម្មរបស់ពួកគេ។

៣- **ឧបសម្ព័ន្ធទី**I ត្រូវដាក់ដើម្បីផ្តល់ជូនដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានានូវសេចក្តីរៀបរាប់ដោយត្រួសៗអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលសហព្រះរាជអាជ្ញាបានស្វែងរកសុំឲ្យធ្វើការកោះហៅ ក៏ដូចជាដីកាដែលស្នើឡើង បានលើកអនុសាសន៍ឲ្យកោះហៅបុគ្គលទាំងនោះមកផ្តល់សក្ខីកម្ម។ ឧបសម្ព័ន្ធនេះរួមបញ្ចូលផងដែរសាក្សីបម្រុងដែលបានស្នើសុំ។

*វិធានការការពារ*

៤- នៅក្នុង**ឧបសម្ព័ន្ធទី**II មានសេចក្តីរៀបរាប់លម្អិតអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញគ្រប់រូប ដែលសហព្រះរាជអាជ្ញាមានបំណងចង់ឲ្យកោះហៅនៅក្នុងពេលជំនុំជម្រះ។ សហព្រះរាជអាជ្ញាមិនមានបំណងចង់និយាថាតើបុគ្គលទាំងនេះតម្រូវឲ្យមានវិធានការការពារដែរ ឬក៏អត់នោះទេ ហើយថាតើត្រឹមកម្រិតណា ដោយសារតែ សហព្រះរាជអាជ្ញាមិនមានសិទ្ធិជួប និងពិភាក្សាបញ្ហាទាំងនេះ

ជាមួយពួកគេឡើយ។ ហេតុដូចនេះ តាមមាត្រា៣៣ថ្មីនៃច្បាប់ អវតក និងតាមវិធាន២៩(៣)នៃវិធានផ្ទៃក្នុង ដោយសារតែការពិតថា សហព្រះរាជអាជ្ញាមិនបានជួបទាក់ទងជាមួយសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងនោះទេ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការណែនាំដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (“អង្គភាពWESU”) ដើម្បីឲ្យជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ថាតើគួរស្វែងរកវិធានការការពារសម្រាប់បុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងបញ្ជីនានារបស់សហព្រះរាជអាជ្ញាដែរ ឬទេ។ ក៏ស្នើដែរឲ្យអង្គភាព WESU ស្រង់ឲ្យបាននូវព័ត៌មានជាក់លាក់អំពីបុគ្គលជាសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញម្នាក់ៗ ដូចជាអំពីប្រភេទនៃវិធានការការពារដែលពួកគេអាចនឹងយល់ឃើញថាជាការចាំបាច់។

*ការធ្វើសម្បថ ឬធ្វើសច្ចាប្រណិធាន*

៥- ក្នុងករណីដែលអាចធ្វើទៅកើត សហព្រះរាជអាជ្ញាបានដាក់បញ្ចូលប្រភេទនៃសម្បថ ឬសច្ចាប្រណិធានដែលអ្នកជំនាញ និងសាក្សីម្នាក់ៗ រំពឹងថានឹងធ្វើក្នុងអំឡុងពេលសវនាការ។ ជាទូទៅទោះបីយ៉ាងណាក៏ដោយ ព័ត៌មាននេះមិនមាននៅចំពោះមុខសហព្រះរាជអាជ្ញាទេ។ នៅពេលកំណត់ហេតុស្តាប់ចម្លើយសាក្សីត្រូវបានសម្ភាស ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ជាទូទៅបញ្ជាក់ថាតើបុគ្គលនោះត្រូវស្បថ ឬសច្ចាប្រណិធានស្របតាមវិធាន៣១ ឬវិធាន២៤(១)នៃវិធានផ្ទៃក្នុង។ កំណត់ហេតុទាំងនោះមិនបានបញ្ជាក់អំពីប្រភេទនៃសម្បថទេ។ ក្រៅពីនេះបុគ្គលទាំងអស់ដែលមិនទាន់បានសម្ភាសដោយការិយាល័យសហចៅក្រមស៊ើបអង្កេត គឺមិនតម្រូវឲ្យធ្វើសម្បថនៅឡើយទេ។ ដូចនេះ សិទ្ធិរបស់គេក្នុងបញ្ហានេះ មិនបានដឹងទេនាពេលបច្ចុប្បន្ននេះ។

៦- សហព្រះរាជអាជ្ញាក៏បានធ្វើការកត់សម្គាល់ផងដែរថា ទាក់ទងទៅនឹងវិធាន៨០(១) ដែលសហព្រះរាជអាជ្ញាមិនទាន់មានសិទ្ធិក្នុងការចូលទៅពិនិត្យព័ត៌មានឲ្យបានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យខ្លួនធ្វើសេចក្តីថ្លែងអំពី ថាតើសាក្សីទាំងឡាយមានបានធ្វើទំនាក់ទំនងជាមួយដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ដែរ ឬទេ ដែលអាចធ្វើឲ្យពួកគេមិនធ្វើសម្បថអនុលោមតាមវិធាន២៤(២)នៃវិធានផ្ទៃក្នុង។ នេះគឺដោយហេតុថាដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើននៃសំណុំរឿងលេខ០០២ មិនត្រូវបានទទួលយក និងមិនត្រូវបានកំណត់អត្តសញ្ញាណដោយសហចៅក្រមស៊ើបអង្កេតទេ រហូតទល់ក្រោយការធ្វើសម្ភាសន៍សាក្សីត្រូវបានធ្វើរួចរាល់។ ហេតុដូចនេះ សហព្រះរាជអាជ្ញាក៏ស្នើផងដែរឲ្យអង្គជំនុំជម្រះសាលាដំបូងស្នើសុំ

ជំនួយពីអង្គភាព WESU ដើម្បីកំណត់ថា តើសាក្សីទាំងឡាយដែលនៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា មានការជាប់ទាក់ទងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ ដែលបានទទួលយករួចហើយដែរ ឬទេ។

## ***ការជ្រើសរើសយកការពិចារណា***

៧- សហព្រះរាជអាជ្ញាបានស្នើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសម្រាប់សវនាការនេះ ក្នុងគំនិតដើម្បីឲ្យមានតុល្យភាពនៅក្នុងការស្វែងរកការពិត ចំពោះអង្គហេតុទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងការការពារសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវរបស់ជនជាប់ចោទ និងនៅក្នុងការជួយសម្រួលដល់ភាពចាំបាច់នៃការសន្សំសំចៃរបស់តុលាការ។ យ៉ាងហោចណាស់ សក្ខីកម្មរបស់បុគ្គលទាំងនេះសំខាន់ចំពោះសមត្ថភាពរបស់សហព្រះរាជអាជ្ញា នៅក្នុងការបង្ហាញភស្តុតាងឲ្យហួសពីវិមតិសង្ស័យ ដូចវិធាន៨៧(១) ចំពោះឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង០០២/០២។

៨- ភាគច្រើននៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា ត្រូវបានកំណត់អត្តសញ្ញាណជូនអង្គជំនុំជម្រះសាលាដំបូង កាលពីខែមេសា ឆ្នាំ២០១១ គឺនៅពេលដែលតម្រូវឲ្យសហព្រះរាជអាជ្ញាដាក់បញ្ជីនោះ ដែលខ្លួនចង់ឲ្យកោះហៅមកក្នុងសវនាការក្នុងសំណុំរឿង០០២ នៅមុនពេលបំបែកកិច្ចដំណើរការនីតិវិធី។ ប៉ុន្តែ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញខ្លះ មិនឋិតនៅក្នុងបញ្ជីអាទិភាពទេ នៅពេលនោះសហព្រះរាជអាជ្ញាមិនបានដឹងអំពីព័ត៌មានដែលបុគ្គលម្នាក់ៗបានផ្តល់ជូន ឬទោះបីជាសហព្រះរាជអាជ្ញាបានដឹងអំពីព័ត៌មាននេះក៏ដោយ ក៏សហសហព្រះរាជអាជ្ញាយល់ថា បើធ្វើការប្រៀបធៀបសក្ខីកម្មរបស់ពួកគាត់ទាំងនោះគឺមានសារៈសំខាន់តិចជាងសាក្សីដទៃទៀតដែលកំពុងស្នើឡើងនៅក្នុងសវនាការលើកទីមួយ ជាពិសេសដោយសារចំនួនសាក្សីមានកម្រិត ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលអាចនឹងកោះហៅមកផ្តល់សក្ខីកម្ម។

៩- ពេលនេះ សហព្រះរាជអាជ្ញាបានវាយតម្លៃជាថ្មីលើភស្តុតាងរបស់សាក្សីទាំងនេះថាមានសារៈសំខាន់សម្រាប់សវនាការលើសំណុំរឿង០០២/០២ និងក្នុងការពិចារណាអំពីភស្តុតាង និងសក្ខីកម្មផ្ទាល់មាត់

ដែលបានស្តាប់ក្នុងសំណុំរឿង០០២/០១។ បុគ្គលទាំងនោះ ជាកម្មវត្ថុនៃសំណើដល់អង្គជំនុំជម្រះសាលាដំបូងដែលបានដាក់រួមគ្នាដោយភាគីទាំងអស់។ ក្នុងសំណើនេះ ពាក់ព័ន្ធនឹងវិធាន ៨៧.៤ ស្តីពីការទទួលយកភស្តុតាង ទាក់ទងនឹងភស្តុតាងថ្មីដែលបានស្នើដោយភាគីមួយ ភាគីស្នើថាបទប្បញ្ញត្តិនេះអនុវត្តតែភស្តុតាងថ្មីដែលត្រូវបានស្នើ បន្ទាប់ពីការបើកសវនាការ គឺថានៅក្រោយពេលសវនាការបឋមខាងមុខនេះ[3]។ ចាប់ពីកាលបរិច្ឆេទនៃការដាក់ឯកសារនេះ ពុំមានសេចក្តីសម្រេចណាមួយបានធ្វើនោះទេ ចំពោះសំណើនេះ។

១០- មានបុគ្គលខ្លះដែលមិនបានដាក់ចូលទៅក្នុងបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញា ដោយផ្អែកលើមូលដ្ឋានថា គេនឹងត្រូវបានអនុញ្ញាតឲ្យបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារពាក់ព័ន្ធជាភស្តុតាង បន្ថែមពីលើឯកសារទាំងឡាយដែលបានទទួលយករួចហើយនៅក្នុងសំណុំរឿង០០២/០២ ពីសំណុំរឿង០០២/០១[4] ដោយអនុលោមតាមវិធាន៨៧។ ប៉ុន្តែក្នុងករណីដែលកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬឯកសារដែលពាក់ព័ន្ធ មិនត្រូវបានទទួលយកនោះសហព្រះរាជអាជ្ញារក្សាសិទ្ធិស្នើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញបន្ថែម ដើម្បីស្តាប់សក្ខីកម្មក្នុងពេលសវនាការ មតិរបស់សហព្រះរាជអាជ្ញា ប្រសិនបើការច្រានចោលឯកសារភស្តុតាងដូច្នេះ គឺធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពក្នុងការបំពេញបទដ្ឋាននៃការបង្ហាញភស្តុតាងដែលជាលក្ខខណ្ឌតម្រូវចំពោះបញ្ហាសម្ភារៈជាក់លាក់ណាមួយ នៅក្នុងសវនាការក្នុងសំណុំរឿង០០២/០២។

១១- បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដូចបានកំណត់អត្តសញ្ញាណក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា មិនអាចមកបង្ហាញខ្លួននៅពេលសវនាការដោយសារមូលហេតុណាមួយ ឬបើសិនជាពួកគាត់បង្ហាញខ្លួននៅពេលសវនាការ ហើយមិនអាចបង្ហាញអង្គហេតុដូចមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ពួកគាត់ទេ សហព្រះរាជអាជ្ញាក៏ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងផងដែរថា សហព្រះរាជអាជ្ញាអាចស្នើស្តាប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញបម្រុងវិញសក្ខីកម្មលើបញ្ហាដដែល ឬស្រដៀងគ្នា។ ឈ្មោះបុគ្គលទាំងនេះត្រូវបានផ្តល់ជូនតាមលទ្ធភាពដែលអាចធ្វើបាននៅក្នុង **ឧបសម្ព័ន្ធ I, IIក និង IIIក**។

[3] **E307** សំណើរួមរបស់ភាគីសុំការបំភ្លឺ អំពីការអនុវត្តវិធាន ៨៧(៤) នៅក្នុងសំណុំរឿង០០២/០២, ៣០ មេសា ២០១៤។

[4] **E302/5** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការបញ្ជាក់បំភ្លឺទាក់ទងនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញជាថ្មីឡើងវិញពីសំណុំរឿង០០២/០១ សម្រាប់សំណុំរឿង០០២/០២", ៧ កុម្ភៈ ២០១៤។

១២- នៅក្នុង **ឧបសម្ព័ន្ធ** I សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបម្រុងទាំងនេះ ត្រូវបានចុះបញ្ជីថា "បម្រុង" នៅក្រោមវគ្គសវនាការនេះដែលយើងជឿថា ពួកគាត់អាចផ្តល់ភ័ស្តុតាងភវនីយដ៏ល្អបំផុត។ សហព្រះរាជអាជ្ញាបានខិតខំប្រឹងប្រែងដោយសុចរិត ដើម្បីកំណត់អត្តសញ្ញាណសាក្សីបម្រុងដែលមានសក្តានុពល ក្នុងដំណាក់កាលនេះ បើទោះជាការប្រើប្រាស់សាក្សីបម្រុងទាំងនេះ នឹងត្រូវពឹងផ្អែកទៅលើកាលៈទេសៈជាក់លាក់នៃការជំនុំជម្រះក៏ដោយ ដែលអាចនឹងត្រូវការជាចាំបាច់នូវសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីខុសៗគ្នា ជាជាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលពេលនេះបានចុះបញ្ជីថា "បម្រុង" នោះ។ **ឧបសម្ព័ន្ធ** IIក និង IIIក ផ្តល់ព័ត៌មានដូចគ្នា សម្រាប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញ "បម្រុង" ដូចដែលអង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យសហព្រះរាជអាជ្ញាស្នើបុគ្គលដែលខ្លួនមានបំណងកោះហៅនៅក្នុងពេលសវនាការ នៅក្នុង **ឧបសម្ព័ន្ធ II និង III** ជាបន្តបន្ទាប់គ្នា។

១៣- និយាយក្នុងលក្ខណៈទូទៅជាងនេះ នៅពេលសវនាការដំណើរការទៅមុខ ប្រសិនបើសហព្រះរាជអាជ្ញាជឿថា ចាំបាច់ត្រូវការកោះហៅសាក្សីបន្ថែមលើបញ្ហាជាក់លាក់ណាមួយ ដើម្បីបំពេញបន្ទុកភ័ស្តុតាងរបស់ខ្លួន នោះសហព្រះរាជអាជ្ញារក្សាសិទ្ធិស្នើសាក្សីបន្ថែមជូនអង្គជំនុំជម្រះសាលាដំបូង នៅក្នុងពេលនោះតែម្តង។

១៤- មានបុគ្គលខ្លះដែលសហព្រះរាជអាជ្ញាស្នើឲ្យកោះហៅ មិនបានស្តាប់សម្ភាសដោយ កសចស ទេ។ អ្នកទាំងនោះ រួមមាន អ្នកជំនាញដែលភាគច្រើនត្រូវដែលបានស្នើឡើង។ កសចស មិនបានស្តាប់ចម្លើយបុគ្គលទាំងនោះទេ ដែលពួកគាត់មានជំនាញទូលំទូលាយលើបញ្ហាដែលពាក់ព័ន្ធនឹងកម្មវត្ថុដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ផ្ទុយទៅវិញ ការបោះពុម្ពផ្សាយរបស់ពួកគាត់ត្រូវបានដាក់នៅក្នុងសំណុំរឿង។ ការពិតដែលថាអ្នកជំនាញទាំងនេះមិនបានផ្តល់ចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មិនបានបន្ថយតម្លៃសក្ខីកម្មរបស់ពួកគាត់ទេ។ តាមពិតបុគ្គលទាំងនេះកំពុងស្ថិតក្នុងគោលជំហរក្នុងការផ្តល់ឲ្យនូវទិដ្ឋភាពពិសេស ជាញឹកញាប់ នៅលើបញ្ហាទូលំទូលាយជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ និងរបៀបមួយច្បាស់លាស់ដែលនាំទៅដល់ការជួយសន្សំសំចៃរបស់តុលាការ។

## ***ការរៀបចំសវនាការ លំដាប់សាក្សី និងពេលវេលាប៉ាន់ស្មាន***

១៥- ដូចសវនាការសំណុំរឿង០០២/០១ដែរ គេបានស្នើឱ្យបែងចែកជាដំណាក់កាលសម្រាប់សវនាការក្នុងសំណុំរឿង០០២/០២ ដោយផ្តោតលើគោលនយោបាយសហកម្មឧក្រិដ្ឋកម្មរួម និងព្រឹត្តិការណ៍ព្រហ្មទណ្ឌ និងទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធផ្សេងទៀតដែលជាកម្មវត្ថុនៃសវនាការ។ ក្នុងដំណាក់កាលនិមួយៗ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ត្រូវបែងចែកជាក្រុម ដោយផ្អែកទៅលើព្រឹត្តិការណ៍ ឬទីតាំងឧក្រិដ្ឋកម្មជាក់លាក់ដែលថាពួកគាត់អាចផ្តល់ភ័ស្តុតាងភស្តុតាងដែលមានតម្លៃបំផុត។ បន្ថែមលើព្រឹត្តិការណ៍ និងទីតាំងឧក្រិដ្ឋកម្មដែលបានជ្រើសយកដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០២ សហព្រះរាជអាជ្ញាស្នើឱ្យមានដំណាក់កាលបន្ថែមមួយ ដើម្បីស្តាប់សាក្សីបន្ថែមអំពីតួនាទីរបស់ជនជាប់ចោទ នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម។ សហព្រះរាជអាជ្ញាសន្និដ្ឋានថាសំណើសុំបែបបទសម្រាប់ការបង្ហាញភ័ស្តុតាងនៅក្នុងសំណុំរឿង០០២/០២របស់ខ្លួន នឹងធ្វើឱ្យមានប្រសិទ្ធភាពជាអតិបរមានៃកិច្ចដំណើរការនីតិវិធី និងជួយសម្រួលដល់គូភាគី ការយល់ដឹងរបស់អង្គជំនុំជម្រះសាលាដំបូង និងរបស់សាធារណជនចំពោះសំណុំរឿងនេះ។

១៦- អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាស្នើឱ្យបែងចែកការជំនុំជម្រះសំណុំរឿង០០២/០២ ទៅជាប្រាំដំណាក់កាល និងវគ្គឆ្លើយឆ្លងគ្នាដូចខាងក្រោម៖

(១) **តួនាទីរបស់ជនជាប់ចោទ**

(២) **មន្ទីរសន្តិសុខ៖** (ក) ស-២១, (ខ) ការបោសសម្អាតផ្ទៃក្នុង, (គ) សហករណ៍ក្រាំងតាចាន់/ត្រាំកក់, (ឃ) អូរកន្សែង និង (ង) ភ្នំក្រោល។ ក្នុងដំណាក់កាលនេះ សូមស្នើថា ***គោលនយោបាយស្តីពីសហករណ៍*** (កម្រិតត្រឹមតំបន់ត្រាំកក់) ក៏ត្រូវស្តាប់សវនាការដែរ ដោយសារមានសាក្សី ឯកសារ និងបញ្ហាផ្សេងៗមានលក្ខណៈដូចគ្នាច្រើន ជាមួយក្រាំងតាចាន់ ដែលជាមន្ទីរសន្តិសុខស្រុកត្រាំកក់។

(៣) **ការប្រព្រឹត្តិចំពោះក្រុមគោលដៅ៖** (ក) វៀតណាម និង (ខ) ចាម។ ក្នុងដំណាក់កាលនេះ សូមស្នើថា ***គោលនយោបាយបន្លាស់ទីប្រជាជន*** (កម្រិតត្រឹមការប្រព្រឹត្តិលើចាម នៅក្នុងដំណាក់ទី២) ក៏ត្រូវស្តាប់សវនាការដែរ ដោយសារមានភស្តុតាងដូចគ្នាច្រើនដែលពាក់ព័ន្ធទៅនឹងគោលនយោបាយនានាលើជនជាតិចាម។

(៤) **ទីតាំងការដ្ឋាន៖** (១) ទំបន់ ១ មករា, (ខ) ទំនប់អាងត្រពាំងថ្ម និង (គ) ព្រលានយន្តហោះកំពង់ឆ្នាំង។

(៥) **បទបញ្ជាផ្ទៃក្នុងសម្រាប់អាពាហ៍ពិពាហ៍ (ទូទាំងប្រទេស)។**

១៧- សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា សវនាការលើសំណុំរឿង០០២/០២ ត្រូវចាប់ផ្តើមពីមន្ទីរសន្តិសុខស-២១ ជាកន្លែងឧក្រិដ្ឋកម្មតែមួយគត់ដែលតាំងនៅភ្នំពេញ និងបានរាយការណ៍ ដោយត្រង់ៗឲ្យទៅជនជាប់ចោទក្នុងសំណុំរឿង០០២ ក៏ដូចជាបញ្ហាទាក់ទងនឹងការបោសសម្អាតផ្ទៃក្នុងផងដែរ។ ភស្តុតាងដែលនឹងត្រូវស្តាប់ទាក់ទងនឹង ស-២១ នឹងបង្កើតជាមូលដ្ឋានគោល ហើយផ្តល់ជាឆាក និងផ្តល់ជាបរិបទនៃទីកន្លែងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍នានាដែលនៅសេសសល់ក្នុងសំណុំរឿង០០២។ ចំពោះហេតុផលដូចគ្នានេះដែរ សហព្រះរាជអាជ្ញាស្នើថាគេត្រូវស្តាប់ចម្លើយសាក្សីបន្ថែមទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ នៅពេលចាប់ផ្តើមសវនាការតែម្តង គឺនៅមុនពេល ឬក៏ភ្លាមៗ បន្ទាប់ពីវគ្គស្តីពី ស-២១ និងការបោសសម្អាតផ្ទៃក្នុង។

១៨- សហព្រះរាជអាជ្ញាស្នើថាគេត្រូវដាក់បញ្ហាខាងលើនេះ បន្ទាប់ពីមន្ទីរសន្តិសុខក្រាំងតាចាន់ និងសហករណ៍ត្រាំកក់ ដែលត្រូវជំនុំជម្រះរួមគ្នា ក្នុងគោលដៅប្រសិទ្ធភាពសវនាការ ហើយបន្ទាប់មកមន្ទីរសន្តិសុខដែលនៅសល់ចំនួនពីរទៀត (អូរកន្សែង និងភ្នំក្រោល)។ ឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ចំពោះសហករណ៍ត្រាំកក់ និងក្រាំងតាចាន់ គឺទាក់ទងទៅនឹងសាក្សី និងឯកសារ រួមមាន កំណត់ត្រាសហកាលជាច្រើនដែលគេរកបានពីស្រុកនោះ។ ដោយសារតែភាពទូលំទូលាយនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ក្នុងស្រុកត្រាំកក់ និងដោយសារត្រាំកក់ត្រូវបានទទួលស្គាល់ដោយ បកក ថាជាស្រុកគំរូសម្រាប់កម្ពុជាប្រជាធិបតេយ្យទាំងមូល សវនាការលើភស្តុតាងដែលទាក់ទងនឹងឧក្រិដ្ឋកម្មទាំងនោះ នៅដំណាក់កាលដំបូងគេមួយនៃសវនាការលើសំណុំរឿង០០២/

០២ ក៏នឹងផ្តល់បរិបទសំខាន់មួយ និងជួយសម្រួលដល់សវនាការអំពីទីកន្លែង និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្ម ដែលនៅសេសសល់ទាំងនេះ។

១៩- នៅក្នុងវគ្គសវនាការនីមួយៗ សហព្រះរាជអាជ្ញាបានស្នើឱ្យមានលំដាប់លំដោយជាទូទៅមួយអំពីសាក្សីទាំងឡាយ។ សហព្រះរាជអាជ្ញាបានស្នើឱ្យស្តាប់ចម្លើយរបស់អ្នកជំនាញនៅពេលចាប់ផ្តើមដំបូង ឬនៅចុងបញ្ចប់វគ្គ ឬចុងផ្នែកជាក់លាក់ណាមួយដែលដោះស្រាយទិដ្ឋភាពនានាក្នុងមុខជំនាញឯកទេសរបស់ពួកគាត់។ ធ្វើដូច្នេះ ភស្តុតាងរបស់សាក្សីឃើញផ្ទាល់ភ្នែកនានា អាចដាក់បញ្ចូលក្នុងបរិបទដែលមានភស្តុតាងស្រដៀងគ្នា ដែលអ្នកជំនាញទាំងនោះបានពិភាក្សាដេញដោលហើយ តាមរយៈនេះអនុញ្ញាតឱ្យមានការយល់ដឹងកាន់តែទូលំទូលាយអំពីភស្តុតាងនោះ។ សម្រាប់ហេតុផលដូចគ្នានេះដែរ សហព្រះរាជអាជ្ញាស្នើថាផ្នែកផលប៉ះពាល់ទៅលើជនរងគ្រោះត្រូវធ្វើ នៅពេលចុងបញ្ចប់នៃទីកន្លែង ឬព្រឹត្តិការណ៍ឧក្រិដ្ឋនីមួយៗដែលនៅក្នុងនោះ គេអាចស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានរងផលប៉ះពាល់ដោយសារទីកន្លែង ឬព្រឹត្តិការណ៍ឧក្រិដ្ឋទាំងនោះ។

២០- សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញជាច្រើន នឹងត្រូវផ្តល់ភស្តុតាងដែលទាក់ទងទៅនឹងបញ្ហានានា, ទីកន្លែង និងព្រឹត្តិការណ៍ឧក្រិដ្ឋជាច្រើន។ ដើម្បីកុំឱ្យសាក្សីដដែលចូលបង្ហាញខ្លួនច្រើនដង ឬខណ្ឌចែកសក្ខីកម្មរបស់ពួកគាត់ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ភាគីនានាគួរមានលទ្ធភាពតាំងសំណួរដេញដោលបុគ្គលនោះលើគ្រប់បញ្ហាទាំងអស់ ដែលទាក់ទងនឹងសំណុំរឿង០០២/០២ ដែលពួកគាត់អាចផ្តល់សក្ខីកម្មបាន។

២១- ជាការពិតហើយ សហព្រះរាជអាជ្ញាបានដឹងថា ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី នឹងដាក់ជូននូវសំណើផ្ទាល់របស់ពួកខ្លួនអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលផ្តល់សក្ខីកម្មនៅពេលសវនាការ។ សហព្រះរាជអាជ្ញាស្នើថា គេគួរដាក់បុគ្គលទាំងនេះទៅតាមលំដាប់លំដោយ ដែលមាននៅក្នុងទម្រង់ដែលសហព្រះរាជអាជ្ញាបានដាក់ជូនជាប្រយោជន៍ ដើម្បីឱ្យភស្តុតាងជួយដល់ភាគីណាមួយ អាចត្រូវបានស្តាប់នៅក្នុងបរិបទដែលជាប់ទាក់ទិនខ្លាំង។

២២- ការប៉ាន់ប្រមាណពេលវេលា ត្រូវបានធ្វើឡើងនៅលើមូលដ្ឋានមួយដែលសហព្រះរាជអាជ្ញាអាចមានលទ្ធភាពតាំងសំណួរដេញដោលលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ យ៉ាងហោចណាស់ចាប់ពីមួយភាគបី ទៅដល់ពាក់កណ្តាលនៃពេលវេលាដែលបានបញ្ជាក់នៅក្នុង **ឧបសម្ព័ន្ធ I**។

២៣- ចំនួនសាក្សីមានកំណត់នៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា មានព័ត៌មានស្តីពីអត្តសញ្ញាណរបស់ពួកគេបានកោសលុប និងម្យ៉ាងទៀតបានយោងដោយរហស្សនាម ដូចជា OCP-01។ ទាំងនេះគឺជាសាក្សីដែលសក្ខីកម្មរបស់ពួកគេគ្រាន់តែបានទាញចំណាប់អារម្មណ៍របស់សហព្រះរាជអាជ្ញា តាមរយៈបទសម្ភាសន៍នានាដែលបានធ្វើដោយសហចៅក្រមស៊ើបអង្កេត ហើយបច្ចុប្បន្នដាក់ចំណាត់ថ្នាក់ថាសម្ងាត់។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សុំឱ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយទាំងនោះជូនអង្គជំនុំជម្រះសាលាដំបូង និងភាគី ដោយអមជាមួយនឹងសម្ភារៈដទៃទៀតដែលបានពីកិច្ចស៊ើបសួរដែលកំពុងធ្វើដែលអាចពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២។

២៤- នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធសំណើនេះ "នៅក្នុងដំណាក់កាលនេះ" ប៉ុន្តែ "នៅតែទទួលយកបណ្តឹង"ចំពោះបញ្ហានេះ[5] ដោយសម្អាងថានៅពេលនេះការដាក់បង្ហាញដូច្នេះ "អាចធ្វើឱ្យមានគ្រោះថ្នាក់ជាសក្តានុពលដល់កិច្ចស៊ើបសួរ"[6]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកត់សម្គាល់ឃើញថា មិនទាន់មានកាលបរិច្ឆេទជាក់លាក់ទេ សម្រាប់ការចាប់ផ្តើមសវនាការសំណុំរឿង០០២/០២[7] និងបញ្ជាក់ថា "នៅពេលណា សចសអ យល់ថាការដាក់បង្ហាញឯកសារទាំងនោះនឹងមិនធ្វើឱ្យខូចដល់ផលប្រយោជន៍នៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងអនុញ្ញាតឱ្យ [សហព្រះរាជអាជ្ញាអន្តរជាតិ] រិះរកការទទួលយកឯកសារទាំងនោះនៅក្នុងសំណុំរឿង០០២/០២"[8] ហើយ "ជូនដំណឹងទៅសហព្រះរាជអាជ្ញាឱ្យបានឆាប់តាមដែលអាចធ្វើបានពេលណាវាបានក្លាយជាបញ្ហាសំខាន់ដែលខ្លួនត្រូវបំពេញកាតព្វកិច្ចទៅតាមសំណើនោះ"[9]។ នៅពេល

---

[5] **CF003-D100/1** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៣ ដែលពាក់ព័ន្ធ ទៅក្នុងសំណុំរឿង ០០២/០២, ៨ ឧសភា ២០១៤ ត្រង់កថាខណ្ឌ១៧។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៣ ដែលពាក់ព័ន្ធ ទៅក្នុងសំណុំរឿង ០០២/០២, ៨ ឧសភា ២០១៤ ត្រង់កថាខណ្ឌ១៧។

[6] *ដដែលដូចខាងលើ* ។

[7] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ១១ [សេចក្តីសម្រេចទាំងពីរ]។

[8] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ១២ [សេចក្តីសម្រេចទាំងពីរ]។

[9] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ១៣ [សេចក្តីសម្រេចទាំងពីរ]។

មានការកំណត់កាលបរិច្ឆេទសវនាការ សហព្រះរាជអាជ្ញាអន្តរជាតិចាត់ការជូនដំណឹងជាបន្ទាន់ដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងបញ្ជាក់ឡើងវិញអំពីសំណើសុំបង្ហាញឯកសាររបស់ខ្លួន។

## **សំណើ**

២៥-អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

(១) កោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ព័ន្ធ I, II និង III** ឲ្យមកផ្តល់ភស្តុតាងនៅក្នុងសវនាការលើសំណុំរឿង ០០២/០២។

(២) ស្តាប់សក្ខីកម្មទាំងឡាយទៅតាមលំដាប់លំដោយ ដែលបានកំណត់នៅក្នុងសំណើនេះ ដែលតាមរយៈនេះ សវនាការត្រូវបែងចែកជាវគ្គៗ ដោយផ្តោតលើគោលនយោបាយសហឧក្រិដ្ឋកម្មរួមជាក់លាក់នានា និងផ្នែកឆ្លើយឆ្លងទាំងឡាយទាក់ទងទៅនឹងការអនុវត្តគោលនយោបាយទាំងនោះ នៅតាមទីកន្លែងឧក្រិដ្ឋកម្មនានា ឬនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ឧក្រិដ្ឋដែលមាននៅក្នុងសំណុំរឿង០០២/០២ (ដូចដែលបានរៀបរាប់លម្អិតនៅក្នុង **ឧបសម្ព័ន្ធ I**)។

(៣) ពិចារណាទុកធ្វើជាសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបម្រុង លើបុគ្គលនានាដែលបានកំណត់អត្តសញ្ញាណរួចហើយ ដូចមាននៅក្នុង **ឧបសម្ព័ន្ធ I, ឧបសម្ព័ន្ធ IIក** និង **ឧបសម្ព័ន្ធ IIIក**។

(៤) បង្គាប់ឱ្យអង្គភាព WESU ផ្តល់ព័ត៌មានចាំបាច់ទាំងអស់ជូនដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់មួយ ដែលទាក់ទងទៅនឹងថាតើវិធានការ ការពារណាមួយដែលចាំបាច់ត្រូវធ្វើចំពោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី នៅទូទាំងកិច្ចដំណើរការនីតិវិធីទាំងនេះ ដោយអនុលោមតាមមាត្រា៣៣ថ្មី និងវិធាន២៩ នៃវិធានផ្ទៃក្នុង។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | [signature] |